# ដំណឹងអាក្រក់
## (Bad News)



*ម៉ោងជាង១១ព្រឹក ពេលថ្មើរនេះមន្ទីរពេទ្យសុខដុមកំពុងតែដំណើរការយ៉ាងមមាញឹក។ នៅឯផ្លូវចូលរថយន្តសម្រាប់ភ្ញៀវ រថយន្តម៉ាកតូយ៉ូតាកូរ៉ូឡាពណ៌សមួយកំពុងបោះពួយតម្រង់ឆ្ពោះទៅទីចំណត។ ស្ទើរតែយានមិនទាន់រលត់ម៉ាស៊ីនស្រួលបួលផង ទ្វារខាងអ្នកបើកបរបានរបើកឃ្វាំងឡើង លេចបុរសមួយរូបហក់ចេញពីក្នុងរថយន្តមកក្រៅ រួចហើយអ្នកបាទនោះក៏រត់យ៉ាងរលះរលាំងសំដៅទៅរកជណ្ដើរយន្ត។ នៅលើជញ្ជាំងខាងស្ដាំ ជាប់នឹងមាត់ទ្វារជណ្ដើរយន្តមានរាយឈ្មោះផ្នែកសំខាន់ៗនៃមន្ទីរពេទ្យនិងគំនូសផែនទីបញ្ជាក់ពីជាន់និងទីកន្លែងដែលផ្នែកនីមួយៗតាំងនៅ។ បុរសងើយមុខ យកដៃចង្អុលទៅលើគំនូសផែនទី តាំងពីខាងលើបំផុត ហើយទាញបង្អួសម្រាមដៃចុះមកក្រោមយ៉ាងលឿន មាត់ទន្ទេញ យ៉ាងរង្គេញ "សង្គ្រោះបន្ទាន់!... សង្គ្រោះបន្ទាន់!..." លុះម្រាមដៃចុចប៉ះនឹងអក្សរ* ***សង្គ្រោះបន្ទាន់*** *នៅលើជញ្ជាំងភ្លាម បុរសដកដៃចេញពីជញ្ជាំងមកចុចលើសញ្ញាព្រួញចង្អុលជាសញ្ញាឡើងលើយ៉ាងរន្ធឹន។ គ្រាន់តែទ្វារជណ្ដើរយន្តរបើកភ្លាម នាយនោះត្បុលសំរុកចូលទៅខាងក្នុងឥតបង្អង់ ហើយយកដៃចុចយ៉ាងធ្ងន់ទៅលើគន្ទឹះលេខ៣។ មិនបង្អង់យូរ ប្រអប់បួនជ្រុងក៏យោងនាយយើងឡើងរឹងទៅជាន់ទីបីនៃអាគារមន្ទីរពេទ្យ។ ពេលចេញពីជណ្ដើរយន្ត ក្រលេកឃើញនាយកងរក្សាសន្តិសុខម្នាក់កំពុងឈរក្បែរនោះ បុរសយើងស្រែកសួរយ៉ាងរហ័សៈ "សុំទោស! តើកន្លែងសង្គ្រោះបន្ទាន់នៅខាងណា?"*

*បុរសក្នុងឯកសណ្ឋានសន្តិសុខ លើកដៃចង្អុលទៅខាងឆ្វេង ទើបតែនឹងហាមាត់តែមិនទាន់បានស្ដីចេញថាយ៉ាងម៉េចផង បុរសជាភ្ញៀវស្រែកថាអរគុណ ហើយបែរមុខដើរផងរត់ផងទៅតាមទិសដែលអ្នកសន្តិសុខចង្អុល។ បុរសនេះទំនងជាមានវ័យជាងសាមសិបឆ្នាំ សម្បុរខ្មៅស្រអែម រាងខ្ពស់ស្រលះ ទឹកមុខគេពេញដោយសភាពភ័យរន្ធត់តក់ស្លុត។ ប្រមាណជាដប់នាទីក្រោយមកជាមួយដង្ហើមហត់ដង្ហក់និងញើសជោកខ្លួងអាវ បុរសស្រអែមបានមកដល់មុខបន្ទប់ដែលអក្សរពណ៌ក្រហមនៅពីលើទ្វារដាក់ថា* ***សង្គ្រោះបន្ទាន់ - Emgergency****។ ទ្វារបន្ទប់បិទជិត ដឹងថាមិនអាចចូលទៅខាងក្នុងបានទេ បុរសយើងបែរប្រាណមកក្រោយវិញ។ នៅពីមុខគេគឺទីកន្លែងរង់ចាំរបស់ញាតិមិត្តនៃអ្នកជំងឺដែលកំពុងទទួលការសង្គ្រោះបន្ទាន់។ នៅទីនេះមានកៅអីចំនួន ប្រាំបីនិងមានមនុស្សបីនាក់អង្គុយរួចជាស្រេច ... ស្ត្រីចំណាស់ម្នាក់កំពុងយំខ្សឹបខ្សួល ដោយមានយុវជនម្នាក់អង្គុយអែបប្រកបដោយទឹកមុខក្រៀមក្រំ រំលងពីយុវជនចំនួនពីរកៅអី មានស្ត្រីមួយរូបក្នុងវ័យជាងម្ភៃឆ្នាំ អង្គុយបែរមុខទៅរកទ្វារបន្ទប់* ***សង្គ្រោះបន្ទាន់*** *តែកែវភ្នែកល្ហល្ហេវដូចជាមនុស្សភាំងបាត់វិញ្ញាណ អាវនាងខាងមុខមានប្រលាក់ឈាមដែលកកទៅហើយប្រឡេកប្រឡាក។ បុរសចំណូលថ្មីក្រលេកឃើញនារីម្នាក់នេះពេលណា ក៏ស្ទុះស្ទាចូលមកជិត ហើយបន្លឺយ៉ាងរហ័ន់ "អ្នកនាងសុភក្ត្រា! គេយ៉ាងម៉េចទៅហើយ? តើមានរឿងអី?"*

*នាងសុភក្ត្រហាក់ភ្ញាក់ស្មារតី ទឹកមុខនាងប្រែមកជាសភាពញាប់ញ័ររន្ធត់ម្ដង នាង ពោលដោយរអាក់រអួល "ហ្ន លោកវិសេស ... ខ្ញុំ ... ខ្ញុំមិនដឹងទេ ... ពេលខ្ញុំទៅដល់ ឃើញគាត់ ... គាត់ដេកដួលលើអំបែងកែវក្នុងផ្ទះបាយទៅហើយ ... គាត់មានរបួស ... ឈាម ...ឈាមច្រើនណាស់ ... ហូរមកអត់ឈប់ ... គួរឱ្យខ្លាច ... គាត់សន្លប់អត់ ដឹងខ្លួនទេ! ... ខ្ញុំខលហៅឡានពេទ្យឱ្យគេនាំគាត់មកមន្ទីរពេទ្យនេះ ... ពេលមកដល់ ពួកគេនាំគាត់ចូលទៅក្នុងបន្ទប់សង្គ្រោះបន្ទាន់បាត់ ... យូរណាស់ហើយ មិនមានដំណឹងពីគាត់សោះ ... គេឱ្យខ្ញុំជួយបំពេញសំណុំបែបបទខ្លះឱ្យគាត់ ... តែក្រៅពីឈ្មោះគាត់ ស្អីក៏ខ្ញុំមិនដឹងដែរ..." និយាយរៀបរាប់ដល់ត្រឹមនេះនាងក៏ឈប់ ទឹកមុខនាងមានសភាពជូរចត់សម្បើមណាស់ នាងឈ្ងោកភ័ក្ត្រ ដកដង្ហើមធំ ហាក់ដូចជាខំប្រឹងទប់ចិត្តកុំឱ្យយំ។*



មិនឮនារីបន្តវាចាទៀត នាយវិសេសក៏ដើរទៅទម្លាក់ខ្លួនអង្គុយលើកៅអីនៅខាងស្តាំដៃនាងសុភក្រ្តា ដោយទុកកៅអីទំនេរមួយនៅចន្លោះគេទាំងពីរ។ បុរសងាកមើលមកនារីជាញឹកញាប់ តែនាងនៅតែឈ្ងោកមុខស្ងាត់ស្ងៀមដដែល។ មាណពចង់ពោលពាក្យខ្លះដើម្បីលួងលោមនាងនិងកម្សាន្តចិត្តខ្លួនឯងថា រតនៈមង្គលប្រហែលជាមិនអីទេ តែនាយនិយាយមិនចេញ។ វិសេសចង់សួរសុភក្រ្តាថាតើនាងទៅជួបរតនៈមង្គលដោយរបៀបណា? នាងនិយាយថាឃើញរតនៈមង្គលដួលសន្លប់នៅក្នុងផ្ទះបាយ ... តើផ្ទះបាយឯណា? ឬផ្ទះរបស់រតនៈមង្គល? បើអញ្ចឹងមែន តើនាងទៅផ្ទះរបស់រតនៈមង្គលធ្វើអ្វីដែរ? ចម្ងល់ចាក់ស្រេះពេញខួរក្បាលនរៈយើង តែ នាយមិនហ៊ានហើបមាត់សួរមួយម៉ាត់សោះ ម្យ៉ាងទៀតនាយខ្លួនឯង ក៏កំពុងតែព្រួយបារម្ភពីសុខទុក្ខរបស់រតនៈមង្គលខ្លាំងណាស់ដែរ។ គ្រាន់តែបានទទួលទូរស័ព្ទ ពីចៅហ្វាយក្រមុំ **ដួង សម្បត្តិសុភក្រ្តា** ថារតនៈមង្គលមានរបួសធ្ងន់ ត្រូវដឹកចូលបន្ទប់សង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យសុខដុម ហើយឱ្យនាយស្រូតមកជាប្រញាប់ វិសេសស្ទើរបាត់អស់ព្រលឹង នាយរត់ចេញពីការិយាល័យយ៉ាងសស្ងើតសស្ងក់ បើកឡានដូចហោះមកទីនេះ ... សំណាងហើយដែលមិនត្រូវប៉ូលីសឃាត់ចាប់ឬផាកពិន័យពីបទបើកបរហួសល្បឿនកំណត់ក្នុងក្រុង។



វិសេសអង្គុយពត់ម្រាមដៃខ្លួនឯងម្តងមួយៗ ដោយទឹកមុខក្រៀមក្រំនិងអារម្មណ៍ច្របូកច្របល់ ... រំពេចនោះទ្វារបន្ទប់សង្គ្រោះបន្ទាន់ម្ខាងក៏របើកឡើង លេចរូបរាងបុរសម្នាក់ក្នុងឯកសណ្ឋានជាគ្រូពេទ្យ ព្រមជាមួយនឹងសំណួរ "តើអ្នកណាជាក្រុមគ្រួសារលោកកែវ រតនៈមង្គល?"

សុភក្រ្តានិងវិសេសស្ទុះក្រោកឈរព្រមគ្នា! ពួកគេបាញ់ខ្សែភ្នែកឆ្ពោះទៅលើមុខលោកគ្រូពេទ្យដោយអាការៈខ្វាយខ្វល់ដូចគ្នា ស្ទើរតែមិនហ៊ានដកដង្ហើមទេ ដ្បិតចិត្តទន្ទឹងរង់ចាំស្តាប់ការប្រកាសដំណឹង។

លោកគ្រូពេទ្យសម្លឹងមុខបុរសនារីមួយគូនេះពីមួយទៅមួយបន្តិចទើបពោលឡើង "ខ្ញុំត្រូវការជួបជាមួយញាតិរបស់អ្នកជំងឺ ព្រោះមានការខ្លះត្រូវពិភាក្សា"

វិសេសលេបទឹកមាត់មួយក្អឹក ឈានបីជំហានទៅជិតលោកគ្រូពេទ្យ ឱនក្បាលចុះបន្តិចទើបងើបមុខស្រដី "សូមជម្រាបលោកគ្រូពេទ្យ ក្រុមញាតិរបស់គេសុទ្ធតែនៅឆ្ងាយ ... ពេលបន្ទាន់ដូច្នេះទាក់ទងមិនទាន់ទេ ... ខ្ញុំជាមិត្តដ៏ជិតស្និទ្ធបំផុតរបស់រតនៈមង្គល ... មានការអី លោកអាចពិភាក្សាជាមួយខ្ញុំបាន"

លោកគ្រូពេទ្យទម្លាក់ស្មា ទំនងជាគ្មានការជ្រើសរើស "បើអញ្ចឹង សូមអញ្ជើញ លោកមកតាមខ្ញុំ" រួចគាត់បែរកាយ នាំដំណើរចេញទៅតាមរបៀងផ្លូវនៃមន្ទីរពេទ្យ។

វិសេសដើរប្រកិតទៅតាមពីក្រោយលោកគ្រូពេទ្យ ឯនាងសុភក្រ្តាក៏ដើរតាមគេពី ក្រោយត្រុកៗទៅដែរ ទោះជាគ្មាននរណាហៅនាងឱ្យរួមដំណើរក៏ដោយ។ ប៉ុន្មាននាទីក្រោយមក ដំណើរយាត្រារបស់អ្នកទាំងបីបានមកបញ្ឈប់នៅពីមុខបន្ទប់មួយ នៅលើផ្ទាំងទ្វារមានស្លាកជាបន្ទះលោហៈពណ៌ទឹកមាសដែលមានចារអក្សរពណ៌ខ្មៅថា **លោកវេជ្ជ. ទេព អនន្ត។** ឈ្មោះនេះ វិសេសធ្លាប់បានឮល្បីថា ជាគ្រូពេទ្យមួយរូបដ៏ជំនាញ។

លោកវេជ្ជបណ្ឌិតទេព អនន្តមានចំណាស់ប្រហែលជិតហុកសិបឆ្នាំហើយ សក់ល្បាយអាចម៍ខ្លា សម្បុរសជ្រះ ថ្ពាសទូលាយ កែវភ្នែកភ្លឺមុត។ មាឌលោកខ្ពស់ល្មម រាងធាត់ដុះក្បាលពោះបន្តិច តែដំណើររហ័សរហួនស្វាហាប់ មិនចាញ់ក្មេងកំលោះឡើយ។ លោកអនន្តមួយលគន្លឹះរុញទ្វារឱ្យបើកចំហឡើង ហើយលាតដៃជាសញ្ញាអញ្ជើញភ្ញៀវទាំងពីរឱ្យចូលទៅក្នុងបន្ទប់មុន។ ពេលបុរសនារីយើងចូលផុតពីមាត់ទ្វារ ទើបលោកវេជ្ជបណ្ឌិតចូលទៅតាមក្រោយ ដោយទាញទ្វារបិទផង។ លោកគ្រូពេទ្យដើរយ៉ាងលឿនបង្ហួសភ្ញៀវសំដៅទៅតុការិយាល័យដែលបែរមុខទៅរកមាត់ទ្វារចេញ-ចូល។ នៅលើជញ្ជាំងក្រោយតុការិយាល័យនេះ មានព្យួរសញ្ញាប័ត្រផ្សេងរបស់លោកអនន្តជាច្រើនសន្លឹកដែលសុទ្ធតែដាក់ក្នុងស៊ុមយ៉ាងស្អាត។

លោកអនន្តលាតដៃចង្អុលទៅកៅអីទាំងពីរដែលតាំងនៅពីមុខតុការិយាល័យ ដោយស្រដីថា "សូមអញ្ជើញអង្គុយ!" ហើយលោកដើរទៅខាងក្រោយតុ។ ក្រោយដែលភ្ញៀវទាំងពីរដាក់បង្គុយរួចហើយ លោកគ្រូពេទ្យក៏អង្គុយចុះដែរ។

វិសេសនិងសុភក្ត្រាបាញ់ខ្សែភ្នែកចង់ដឹងលើផ្ទៃមុខលោកអនន្តព្រមគ្នា។ លោកដុកទ័រហាក់យល់ចិត្តភ្ញៀវទាំងពីរនេះច្បាស់ ក៏ចាប់ផ្តើមកិច្ចសន្ទនាចូលសាច់ការភ្លាម "ខ្ញុំ គ្រូពេទ្យទេព អនន្ត ..." ពោលបណ្តើរ លោកហុចដៃស្តាំគាត់មករកវិសេសបណ្តើរ។

វិសេសក៏លូកដៃទាំងពីរទៅចាប់រលាក់ដៃលោកវេជ្ជបណ្ឌិតបន្តិច តាមកិច្ចស្វាគមន៍គ្នានៃវប្បធម៌ពួកបច្ចិមប្រទេស ហើយប្រញាប់ធ្វើការណែនាំខ្លួនដែរ "ខ្ញុំបាទ សែន វិសេស"

ពេលលោកអនន្តបែរភ្នែកចំ នាងសុភក្ត្រារហ័សលើកហត្ថប្រណម "ជម្រាបសួស្តី នាងខ្ញុំ ដួង សម្បត្តិសុភក្ត្រា"

លោកវេជ្ជបណ្ឌិតលើកដៃសំពះតបមកនាងកញ្ញាវិញ ហើយពោលបន្ត "ក្នុងពេលឥឡូវនេះ ស្ថានភាពរបស់លោកកែវ រតនៈមង្គល ពុំគួរឱ្យបារម្ភណាស់ណាទេ ... លោកបានរួចផុតពីគ្រោះថ្នាក់ក្នុងគ្រានេះហើយ..." បានឮដល់ត្រឹមនេះ ភ្ញៀវទាំងពីរហាក់បានធូរទ្រូងបន្តិច តែពួកគេមិនទាន់បានស្រាយទឹកមុខផង វាចាលោកអនន្តក៏លាន់បន្ត "គ្រោះថ្នាក់ដែលកើតឡើងក្នុងថ្ងៃនេះ អាចចាត់ទុកថាជារឿងបន្ទាប់បន្សំប៉ុណ្ណោះ បើប្រៀបធៀបនឹងស្ថានភាពជំងឺដែលគាត់កំពុងឆ្លងកាត់។

"លោករតនៈមង្គលធ្លាប់បានសុំឱ្យពួកយើងទុករឿងនេះជាការណ៍សម្ងាត់ តែខ្ញុំគិតថាល្មមដល់ពេលដែលអ្នកជិតស្និទ្ធរបស់គាត់បានដឹងពីការពិត ដើម្បីមានឱកាស ត្រៀមលក្ខណៈផ្លូវចិត្ត និងអាចថែរក្សាគាត់ឱ្យបានល្អផង..." លោកអនន្តបង្អង់សម្តី គាត់ឈ្ងោកមើលម្រាមដៃរបស់គាត់ដែលដាក់បញ្ច្រាសចូលគ្នាបន្តិច ទើបងើបមុខសម្លឹងបុរសនារីទាំងគូដោយកែវភ្នែកស្រងូតស្រងាត់ "លោករតនៈមង្គលកំពុងរងទូវជំងឺមហារីកយ៉ាងធ្ងន់ធ្ងរ ពេលវេលាដែលនៅសល់របស់គាត់មានមិនច្រើនទេ..."



សុភក្ត្រានិងវិសេសភាន់ភាំងស្មារតីដល់ថ្នាក់គាំងអណ្តាតស្តីអ្វីមិនចេញ ទឹកមុខគេស្ញេកស្ញាំង បើកភ្នែកសម្លឹងភ័ក្ត្រលោកអនន្តហាក់មិនចង់ជឿនូវអ្វីដែលលោកបាននិយាយចេញមកមុននេះ។

លោកគ្រូពេទ្យក៏រៀបរាប់ជាបន្ត "លោករតនៈមង្គលមានជំងឺមហារីកគល់ពោះវៀន colon cancer តែជំងឺបានរាលដាលបំផ្លាញដល់សរីរាង្គខាងក្នុងផ្សេងទៀតជាពិសេសគឺថ្លើម ... ជំងឺនេះ ភាគច្រើនគឺកើតមានចំពោះមនុស្សដែលមានអាយុចាប់ពីហាសិបឆ្នាំឡើងទៅ ... វាជារឿងអកុសលណាស់ដែលលោករតនៈមង្គលត្រូវមករងជំងឺអភ័ព្វនេះទាំងក្មេងវ័យ... បើអាចតាមដានដឹងតាំងពីដំបូង ជំងឺនេះប្រហែលជាអាចព្យាបាលឱ្យសះស្បើយបាន ប៉ុន្តែទម្រាំតែលោករតនៈមង្គលចូលខ្លួនមកពិនិត្យសុខភាពនៅមន្ទីរពេទ្យនេះ សភាពជំងឺរបស់គាត់បានឈានចូលដល់ដំណាក់ កាលចុងក្រោយទៅហើយ ... ឱកាសជោគជ័យនៃការព្យាបាលមានស្តួចស្តើងបំផុត គឺមិនដល់ប្រាំភាគរយផងទេ ព្រោះសរីរាង្គខាងក្នុងរបស់គាត់បានទទួលរងនូវការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីការរាតត្បាតនៃកោសិកាមហារីក..."

ដល់ត្រឹមនេះ វិសេសស្រាប់តែសួរកាត់សម្តីលោកគ្រូពេទ្យ "សុំទោស លោកវេជ្ជ បណ្ឌិត ... តើរតនៈមង្គល គេបានដឹងរឿងនេះតាំងពីពេលណាមកដែរ?"



លោកអនន្តបញ្ឆាទៅលើម៉ាស៊ីនកំព្យូទ័របន្តិច ទើបឆ្លើយតប "លោករតនៈមង្គលបានចូលមកពិនិត្យសុខភាពដំបូងនៅថ្ងៃទី២ ខែមិថុនា ... គឺទើបតែជាងមួយខែមុននេះឯង ... ដោយលោកចាប់អារម្មណ៍ថា សុខភាពលោកមានការចុះខ្សោយ ចេះតែហេវហត់ អស់កម្លាំងជាញឹកញាប់ ... ពួកយើងក៏បានធ្វើការពិនិត្យវិភាគយ៉ាងល្អិតល្អន់បំផុត ទើបផ្តល់លទ្ធផលដល់គាត់ក្នុងរយៈពេលបីថ្ងៃក្រោយមក គឺថ្ងៃទី៥ ខែ មិថុនា ... លោករតនៈមង្គលបានទទួលយកដំណឹងអាក្រក់ដោយអារម្មណ៍នឹងនរ ... កាលនោះ គាត់នៅសល់ពេលប្រហែលជាបីទៅបួនខែ ... បើគាត់ព្រមទទួលយកការព្យាបាល យ៉ាងហោចណាស់ ក៏ប្រហែលជាអាចពន្យារជីវិតគាត់បានប៉ុន្មានខែជាបន្ថែមទៀតដែរ ប៉ុន្តែគាត់បដិសេធមិនព្រមទទួលការព្យាបាលទេ ព្រមទាំងសុំឱ្យពួកយើងលាក់ស្ថានភាពជំងឺរបស់គាត់ជាការណ៍សម្ងាត់ទៀតផង ... ពួកយើងគោរពសិទ្ធិនិងការសម្រេចចិត្តរបស់អ្នកជំងឺ ទើបធ្វើតាមសំណូមពរគាត់រហូតមក។

"តែឥឡូវនេះ សុខភាពគាត់ចុះទ្រុឌទ្រោមខ្លាំងណាស់ លឿនជាងការដែលខ្ញុំបានគិតទុក ... អាចបណ្ដាលមកពីការសម្រាកនិងហូបចុកមិនបានជិតដល់ ... លោករតនៈមង្គលលែងមានលទ្ធភាពមើលថែទាំខ្លួនឯងបានទៀតហើយ លោកត្រូវការមានអ្នកមើលថែរក្សា ដើម្បីសម្រាលការលំបាកនិងបញ្ចៀសនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមាន ដូចជារឿងក្នុងថ្ងៃនេះជាដើម ...
"សភាពស្រួចស្រាវនៃជំងឺបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ប្រព័ន្ធរាងកាយ គឺគាត់អាចនឹងធុំអាហារ មិនចង់បរិភោគ ... ប្រព័ន្ធឈាមរត់ចុះខ្សោយ ធ្វើឱ្យសំពាធឈាមចុះទាបនិងមានពេលខ្លះអាចមានការខ្វះឈាមឬខ្វះអុកស៊ីហ្សែនទៅចិញ្ចឹមខួរក្បាលបណ្ដាលឱ្យមានការវិលមុខឬបាត់ស្មារតី ... ហើយការចុះខ្សោយនៃប្រព័ន្ធផលិតឈាមក្រហមអាចធ្វើឱ្យមានបញ្ហាឈាមក្រ កកបើមានការដាច់ហូរឈាម ជាពិសេសគឺការហូរឈាមនៅក្នុងសរីរាង្គខាងក្នុង អាចបង្កផលអាក្រក់ដល់គាត់ច្រើនណាស់..."
និយាយដល់ត្រឹមនេះ លោកអនន្តក៏ចាប់ផ្ដើមសារុបសេចក្ដី "ខ្ញុំគិតថា ក្រុមញាតិរបស់គាត់គួរមានសិទ្ធិដឹងពីរឿងទាំងអស់នេះ ... ខ្ញុំសូមសម្ដែងនូវការសោកស្ដាយចំពោះស្ថានភាពលោករតនៈមង្គល ... ខ្ញុំបានឱ្យគេបញ្ជូនគាត់ ទៅស្នាក់នៅបន្ទប់ពិសេសហើយ គឺបន្ទប់៤២៦ ... លោកនិងនាងអាចចូលទៅសួរសុខទុក្ខគាត់បាន តែគាត់អាចកំពុងស្ថិតក្នុងសភាពទន់ខ្សោយនៅឡើយ ... បើអ្នកទាំងពីរឬក្រុមញាតិរបស់លោករតនៈមង្គលមានការចង់ពិភាក្សាអំពីបញ្ហាផ្សេងៗ ទាក់ទងដល់អាការជំងឺរបស់គាត់គឺអាចទាក់ទងមកខ្ញុំបានគ្រប់ពេល" ពោលចប់ លោកគ្រូពេទ្យក៏ក្រោកឈរឡើង ជាសញ្ញាថាកិច្ចពិភាក្សាបានចូលដល់ទីបញ្ចប់ហើយ។
វិសេសនិងសុភគ្រ្តាក្រោកឈរឡើងដែរ។ លោកអនន្តដើរចេញពីក្រោយតុមកបើកទ្វារជូនដំណើរភ្ញៀវ។ មុននឹងបែរប្រាណចាកចេញពីបន្ទប់ នរៈនិងនារីយើងបានលើកដៃសំពះលា និងថ្លែងវាចាអរគុណដល់លោកវេជ្ជបណ្ឌិតផងដែរ។ បន្ទាប់មកពួកគេក៏បណ្ដើរគ្នាត្រសង ឡើងទៅជាន់ទីបួននៃអាគារមន្ទីរពេទ្យ។
បន្ទប់៤២៦ គឺជាបន្ទប់មួយក្នុងចំណោមបន្ទប់ពិសេស VIP ដទៃទៀតនៃមន្ទីរពេទ្យសុខដុម គឺមានបំពាក់ទៅដោយឧបករណ៍ព្យាបាលដ៏ទំនើបបំផុតនិងគ្រឿងសង្ហារឹមដ៏ប្រណីតមិនចាញ់បន្ទប់សណ្ឋាគារផ្កាយប្រាំឡើយ។ ពេលវិសេសនិងសុភគ្រ្តាបើកទ្វារចូលដល់ក្នុងបន្ទប់ នារីវ័យក្មេងម្នាក់មានមុខមាត់ស្រស់បស់ ស្ថិតក្នុងឯកសណ្ឋានគិលានុបដ្ឋាយិកាបានចេញមកទទួលរាក់ទាក់



"ជម្រាបសួស្ដី! អញ្ជើញមកសួរសុខទុក្ខលោករតនៈមង្គល មែនទេ? លោកទើបតែគេងលក់អម្បាញមិញនេះឯង ...លោកបានទទួលថ្នាំបំបាត់ការឈឺចាប់និងថ្នាំរម្ងាប់អារម្មណ៍ ដើម្បីឱ្យលោកសម្រាកឱ្យបានច្រើន ប្រហែលជាមួយរយៈពេលក្រែលទៀតទើបលោកអាចភ្ញាក់ដឹងខ្លួន ... បើលោកអ្នកទាំងពីរចង់នៅកំដរគាត់ សូមអញ្ជើញតាមសម្រួល ចាំ..."
វិសេសងក់ក្បាល "បាទ៎ ខ្ញុំចង់នៅកំដរគេបន្តិច"
នារីគិលានុបដ្ឋាយិការូបស្រស់ក៏ញញឹមបន្ទី "បើអញ្ចឹង នាងខ្ញុំសុំចេញទៅក្រៅសិនហើយ ... បើមានការអ្វី សូមលោកចុចកណ្ដឹងនៅលើក្បាលគ្រែនុះចុះ ពួកខ្ញុំនឹងមក ដល់ភ្លាម ..." នាងចង្អុលទៅប៊ូតុងពណ៌សមួយដែលនៅលើ ជញ្ជាំងជាប់នឹងក្បាលគ្រែអ្នកជំងឺ។



វិសេសងក់ក្បាលម្ដងទៀត "បាទ៎ អរគុណអ្នកនាង ... សូមអញ្ជើញចុះ" នាងគិលានុបដ្ឋាយិកាក៏បង្វិលកាយបោះជំហានទៅបើកទ្វារចេញក្រៅដោយមិនភ្លេចបិទទ្វារបន្ទប់យ៉ាងជិតដូចដើមវិញ។
ឥឡូវនេះ ក្នុងបន្ទប់នៅសល់តែបុរសនារីមួយគូកំពុងឈរទ្រឹងដូចរូបចម្លាក់ ទឹកមុខប្រកបដោយទុក្ខសោក ភ្នែកក្រហមរលីងរលោង សម្លឹងឥតព្រិចទៅលើរូបអ្នកជំងឺដែលកំពុងគេលក់ឥតកម្រើកនៅលើគ្រែ។ ថ្ងៃបាននាំបាច់រស្មីចាំងបាចសាចចូលតាមកញ្ចក់បង្អួចមកបំភ្លឺបន្ទប់ទាំងមូលយ៉ាងស្រទន់ ... បុរសរងគ្រោះមកពីភូមិវាលស្បូវ ឥឡូវនេះគេលែងមានមុខមាត់ប្រលាក់ប្រលូសដោយលោហិតដូចមុនទៀតហើយ តែបែរជាមានស្បៃពណ៌សរុំជុំថ្ងាស និងមាន បង់បិទរបួសតូចៗពីរនៅលើថ្ពាល់ក្បែរគុម្ពត្រចៀកខាងស្ដាំ។ ប្រាណរបស់គេស្ថិតនៅក្រោមកម្រាលភួយជាសំពត់ពណ៌សដែលដណ្ដប់ពីចុងជើងមកដល់ត្រឹមទ្រូង។

-

គេពាក់អាវដៃខ្លី កម្មលពណ៌ខៀវខ្ចីជាឯកសណ្ឋានអ្នកជំងឺ ... ដៃស្ដាំបត់ដាក់គងលើ ទ្រូង លើខ្នងដៃឆ្វេងដែលដាក់សណ្ដូកតាមដងខ្លួន មានដោតម្ជុលបន្តជាមួយនឹងខ្សែបន្ទោងសេរ៉ូម ... តំណក់សេរ៉ូមកំពុងទម្លាក់ខ្លួនតក់ៗ ហើយហូរសន្សឹមៗ ចូលទៅក្នុងរាងកាយអ្នកជំងឺ។ គេហាក់គេងលក់យ៉ាងស៊ប់ណាស់ទៅហើយ ដង្ហើមស្រាលៗស្មើៗ ផ្ទៃមុខដែលមានសភាពស្ញេកស្ញាំង ហាក់មានភាពស្ងប់ស្ងួតបន្តិចផង ធ្វើឱ្យ អ្នកដែលកំពុងតែសម្លឹងគេមានសេចក្ដីក្ដុកក្ដួលក្នុងចិត្តឥតឧបមា។



បន្ទាប់ពីឈរស្ងៀមដោយក្ដីភ្ញាំងភ្ញឹកអស់ពេលជាយូរ វិសេសស្រាប់តែភ្ញាក់ នឹកឃើញដល់នារីដែលឈរក្បែរកាយ គេបែររកនាងហើយបន្ទឺតិចៗ "អ្នកនាងសុភក្ត្រា សូមអញ្ជើញអង្គុយ" គេលាដៃចង្អុលទៅកៅអីសាឡុងដែលនៅស្ដាំដៃគ្រែអ្នកជំងឺ។

នាងសុភក្ត្រាហាក់ដូចទើបភ្ញាក់ស្មារតីពីការយល់សប្ដិ នាងដកខ្សែភ្នែកពីរង្វង់មុខរតនៈមង្គល មកសម្លឹងមុខវិសេសបន្តិច ទើបងាកចេញទៅសម្លឹងបង្អួចវិញ មាត់នាងបន្ទឺវាចាយ៉ាងខ្សោយ "មិនអីទេ ... ខ្ញុំគិតថាត្រលប់ទៅវិញហើយ ... ថ្ងៃនេះលោកមិនបាច់ ត្រលប់ទៅក្រុមហ៊ុនវិញទេ សូមនៅកំដរមិត្តរបស់លោកឱ្យល្អចុះ" ពោលចប់ នាងបែរមើលទៅរតនៈមង្គលម្ដងទៀត ហើយបម្រុង បែរខ្លួនដើរចេញ តែ ត្រូវវិសេសស្រដីឃាត់ "អ្នកនាងសុភក្ត្រា អ្នកនាងមានទឹកមុខមិនល្អទេ ... ឬបើពុំនោះទេ ចាំខ្ញុំជូនអ្នកនាង ត្រលប់ទៅវិញ"

នារីទុចដំណើរ អារម្មណ៍នាងរំជើបរំជួល តែខំពោលបន្ទប់ "មិនអីទេ ខ្ញុំអាចទៅដោយខ្លួនឯងបាន ... អរគុណលោកហើយ លោកក៏មានទឹកមុខមិនល្អជាងប៉ុន្មាន ដែរ ...លោកនៅមើលការខុសត្រូវទីនេះហើយ" វិសេសនៅតែមិនអស់ចិត្ត គេលើកដៃចង្អុល "អាវអ្នកនាងប្រលាក់សុទ្ធតែឈាម ... បើអ្នកនាងមិនប្រកាន់ទេ សូមយកអាវក្រៅរបស់ខ្ញុំនេះពាក់ពីលើទៅ ដើម្បីកុំឱ្យគេយល់ច្រលំឬសង្ស័យថា អ្នកនាងទើបនឹងមកពីប្រព្រឹត្តឃាតកម្មនៅឯណា ..." បុរសពោលផង ស្រាវដោះអាវក្រៅដែលចំហទ្រូងស្រាប់ ហុចប្រគល់ទៅឱ្យនាងចៅ ហ្វាយក្រមុំផង។

សុភក្ត្រាលូកដៃមកទទួលយកអាវដែលកាត់ដេរចេញពីក្រណាត់ដេនីមពណ៌សពីហត្ថបុរសប្រធានផ្នែកផ្សព្វផ្សាយនិងទីផ្សារនៃក្រុមហ៊ុននាង។ នារីចង់ញញឹមថ្លែងអំណរគុណដល់ការយកចិត្តទុកដាក់របស់អ្នកកំលោះ ប៉ុន្តែសាច់ដុំលើផ្ទៃមុខនាងបានស្ពឹកគាំងអស់ទៅហើយ នាងញញឹមមិនចេញ អាចត្រឹមតែវាចាខ្សឹបៗថា "សុំ អរគុណលោកច្រើន ... ខ្ញុំលាសិនហើយ" ពោលចប់នាងចាកចេញពីបន្ទប់អ្នកជំងឺយ៉ាងលឿន។

មិនមែននាងមិនចង់នៅជិតរតនៈមង្គលទេ នាងចង់នៅមើលថែទាំគេខ្លាំងណាស់ ... នាងចង់រង់ចាំដល់ពេលគេភ្ញាក់ដឹងខ្លួនឡើង ដើម្បីនាងអាចបរិយាយប្រាប់គេអំពីចិត្តរបស់នាង តែនាងក៏មិនដឹងថាត្រូវប្រតិបត្តិខ្លួនបែបណា ក្នុងឋានៈជាអ្វីនៅចំពោះមុខបុរសទាំងពីរនោះ ... វិសេសមុខតែចង់ដឹងថា ហេតុអីនាងបានជួបនិងជួយរតនៈមង្គល ... តើនាងគួរបកស្រាយប្រាប់គេថាដូចម្ដេច? ស្រស់ស្រីមានអារម្មណ៍ថាអស់កម្លាំង ឈឺចាប់ចង់ក្អួត ... នាងចង់ស្រែកយំណាស់! ចង់ទម្លាយភាពណែនស្ទះដែលកកនៅក្នុងទ្រូង ... លើលោកនេះ តើមានអ្នកណាយល់ចិត្តនាងទេ?

សុភក្ត្រាចុះទៅជាន់ក្រោម ដល់កន្លែងទទួលភ្ញៀវនិងផ្ដល់ពត៌មានរបស់មន្ទីរពេទ្យ នាងសុំឱ្យគេយករថយន្តមកឱ្យនាងវិញ។ នាងបានបោះបង់យានជំនិះចោលនៅខាងក្រោយមន្ទីរពេទ្យ ដោយគ្រាន់តែហុចកូនសោរឡានឱ្យទៅនាយកងសន្តិសុខម្នាក់ ព្រោះនាងប្រញាប់ប្រញាល់រត់សស្ទាក់សស្ទន់ទៅតាមរទេះដែលក្រុមសង្គ្រោះកំពុងរុញ រូបកាយស្ដូកស្ដឹងរបស់រតនៈមង្គលចូលទៅក្នុងជណ្ដើរយន្ត។

រង់ចាំប្រហែលដប់នាទី រថយន្តរបស់នាងក៏ត្រូវបានគេនាំមកដល់។ ក្រោយពេលថ្លែងអំណរគុណ និងឱ្យប្រាក់រង្វាន់ដល់អ្នកនាំយានជំនិះមកប្រគល់ឱ្យនាង សុភក្ត្រាចូលក្នុងរថយន្ត បើកចេញវឹងទៅ។


If tomorrow never comes ...
If I knew it would be the last time,
I would be there to share your day
Well I'm sure you'll have so many more,
So I can let just this one slip away.
For surely there's always tomorrow
To make up for an oversight,
And we always get a second chance
To make everything just right.
But just in case I might be wrong,
And today is all I get,
I'd like to say how much I love you
And I hope we never forget.
Tomorrow is not promised to anyone,
Young or old alike,
And today may be the last chance
You get to hold your loved one tight.
So if you're waiting for tomorrow,
Why not do it today?
For if tomorrow never comes,
You'll surely regret the day,
That you didn't take that extra time
For a smile, a hug, or a kiss
And you were too busy to grant someone,
What turned out to be their one last wish.
So hold your loved ones close today,
And whisper in their ear,
Tell them how much you love them
And that you'll always hold them dear
Take time to say "I'm sorry,"
"Please forgive me," "Thank you," or
"It's okay."
And if tomorrow never comes,
You'll have no regrets about today.
Anonymous